# កិច្ចព្រមព្រៀង
# រវាង
# ក្រុមហ៊ុន ស៊ូភៀល (ខេមបូឌា) ឯ.ក
# និង
# ជាមួយសហជីពនិងតំណាងកម្មករនិយោជិតប្រចាំក្រុមហ៊ុន

នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ១៣: ៣០ នាទី រសៀល នៅក្នុងក្រុមហ៊ុន ស៊ូភៀល (ខេមបូឌា) ឯ.ក មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិត ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់ កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារតែក្រុមហ៊ុនយើងខ្វះវត្ថុធាតុដើម ដែលជាហេតុមិនអាចអោយសង្វាក់ផលិតកម្មដំណើរការបាន។ ហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ១២៣០ នាក់ (ស្រី៩១៣ នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ១៦៥៤នាក់ (ស្រី ១១៩៩នាក់) រយៈពេលព្យួរចំនួន ៨ ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី ១ ខែ មេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី ៨ ខែ មេសា ឆ្នាំ២០២៣។ ហើយនៅក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ កម្មករនិយោជិត បានឯកភាពទទួលការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឈ្នួល ១៥ ដុល្លារអាមេរិចក្នុងថ្ងៃព្យួរ ។ ប្រាក់ឈ្នួលនេះនិងបើកជូននៅ ថ្ងៃសុក្រ ទី៣១ ខែមីនា ឆ្នាំ២០២៣ សម្រាប់កម្មករនិយោជិតម្នាក់ៗ ។

អង្គប្រជុំបានចប់នៅវេលាម៉ោង ១៤: ១០ នាទី រសៀល នាថ្ងៃខែឆ្នាំដដែល ដោយភាគីទាំងសងខាងមានភាពស្និតស្នាល និងយោគយល់ និងសហការគ្នាយ៉ាងរលូន។

ថ្ងៃអង្គារ ១៥រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
កំពង់ស្ពឺ, ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣

**នាយកក្រុមហ៊ុន**

ក្រុមហ៊ុន ស៊ូភៀល (ខេមបូឌា) ឯ.ក
រដ្ឋបាល
H.R.D
SUPERL (CAMBODIA) CO., LTD

តាន ធ្វើវង់

**ស្នាមមេដៃតំណាងកម្មករនិយោជិត**

ចន សុផា
ស្រ៊ាន់ ស្រស់
វ៉ាន់ សុខណា
សំា កញ្ញា
យ៉េង ម៉ៅ
កង សេថា
អុន ចាន់ឌី
គាក វ៉ារិច
កង ពិសិដ្ឋ
សាយច័ន្ទរស្មី
លន់ ម៉េងលី
កាញ់ ចាន់ថា
សាធ ប៊ុនភួន